# ផលប៉ះពាល់ជាសក្តានុពលនៃវិបត្តិហិរញ្ញវត្ថុទៅលើគ្រួសារក្រីក្រ និងក្រុមងាយរងគ្រោះ នៅកម្ពុជា

*អត្ថបទនេះជាសេចក្តីសង្ខេបនៃបទបង្ហាញរបស់ បណ្ឌិត Hossein Jalilian[1] ក្នុងវគ្គទី១ នៃសន្និសីទចក្ខុវិស័យ ស្តីពីប្រទេសកម្ពុជា ឆ្នាំ២០០៩ ។*

## សេចក្តីផ្តើម

វិបត្តិហិរញ្ញវត្ថុសាកល ជះឥទ្ធិពលភាគច្រើនទៅលើភាពក្រីក្រ តាមរយៈផលប៉ះពាល់ទៅលើ កំណើនសេដ្ឋកិច្ច ។ ហេតុនេះ ជាដំបូងត្រូវពិចារណាពីផលប៉ះពាល់ទៅលើកំណើនសេដ្ឋកិច្ចនេះ ។ កំណើនសេដ្ឋកិច្ច នៅកម្ពុជាអាចទទួលផលប៉ះពាល់តាមរយៈពាណិជ្ជកម្ម វិនិយោគពីបរទេស ទេសចរណ៍ ការផ្ទេរប្រាក់ និងជំនួយអន្តរជាតិ ជាដើម ។

ផលប៉ះពាល់នៃវិបត្តិ ទៅលើទីផ្សារហិរញ្ញវត្ថុ ទំនងជាមិនធំដុំទេ ពីព្រោះកម្ពុជាមិនទាន់ធ្វើសមាហរណកម្ម ចូលទៅក្នុងទីផ្សារហិរញ្ញវត្ថុសាកល ហើយទីផ្សារហិរញ្ញវត្ថុនៅកម្ពុជានៅអន់ថយនៅឡើយ ។ ទោះយ៉ាងនេះក្តី ផលប៉ះពាល់ដោយប្រយោលទំនងជាមានច្រើនគួរកត់សំគាល់ ។វិបត្តិ បានធ្វើឱ្យសកម្មភាពសេដ្ឋកិច្ចធ្លាក់ចុះ ហើយស្ថានភាពនេះទំនងកាន់តែយ៉ាប់យ៉ឺនថែមទៀត ក្នុងរយៈពេលខ្លី និងមធ្យម ។ រឿងនេះ ទំនងជះឥទ្ធិពលច្រើនណាស់ដល់កំរិត និងលក្ខណៈធ្ងន់ធ្ងរនៃភាពក្រីក្រ ។

## ផលប៉ះពាល់លើកំណើន

ដើម្បីវាយតម្លៃពីផលប៉ះពាល់នៃវិបត្តិទៅលើកំណើន ដំបូងគេគួរពិនិត្យពីផលិតផលក្នុងស្រុកសរុប (ផសស) និងកំណើនតាមវិស័យ ព្រមទាំងចំណែកនៃវិស័យនីមួយៗ នៅក្នុងកំណើនសរុបរបស់កម្ពុជា ។ ក្រាហ្វិក ១ បង្ហាញពីកំណើនតាមវិស័យ និងកំណើន ផសស នៅកម្ពុជា ហើយ ក្រាហ្វិក ២ បង្ហាញពី ចំណែកតាមវិស័យនៅក្នុងកំណើនសរុប ។

នៅឆ្នាំ១៩៩៤-២០០៧ កម្ពុជាមានកំណើន ផសស ជាមធ្យមប្រហែល ១០% ដោយសារកំណើនខ្លាំងក្នុង វិស័យឧស្សាហកម្ម និង វិស័យសេវាកម្មជាទី២ ។ កំណើនវិស័យឧស្សាហកម្ម បានមកពីកំណើនដ៏ខ្ពស់ នៃវិស័យកាត់ដេរ និងសំណង់ ហើយ វិស័យសេវាកម្មកើនឡើងដោយផ្អែកលើវិស័យទេសចរណ៍ ។

វិស័យឧស្សាហកម្ម និងសេវាកម្ម បានចូលរួមចំណែកធំណាស់ក្នុងកំណើន ផសស រីឯវិស័យកសិកម្ម រួមចំណែកមិនសូវច្រើនទេរហូតមកទល់សព្វថ្ងៃ ហើយកំណើនរបស់វាក៏មិនសូវមានស្ថិរភាពដែរ ។

ក្នុងស្ថានភាពបែបនេះ ផលប៉ះពាល់នៃវិបត្តិ ទៅលើកំណើន ផសស នៅកម្ពុជា ទំនងជាមានសភាពធ្ងន់ធ្ងរ ហើយមានការទស្សទាយថា វិស័យឧស្សាហកម្ម និងសេវាកម្ម នឹងត្រូវប៉ះពាល់ខ្លាំងជាងគេ ។ ឧស្សាហកម្មមានកំណើនដោយសារវិស័យកាត់ដេរ និងសំណង់ ប៉ុន្តែវិស័យទាំងពីរនេះ

ក្រាហ្វិក ១: កំណើនតាមវិស័យនៅកម្ពុជា ១៩៩៤-២០០៧




*ប្រភព : ផ្អែកលើទិន្នន័យរបស់វិទ្យាស្ថានជាតិស្ថិតិ*

បានជួបប្រទះការធ្លាក់ចុះ ដែលគេប៉ាន់ស្មានថា នឹងធ្ងន់ធ្ងរឡើងទៀតក្នុងរយៈពេលខ្លី ដោយអាចធ្លាក់ចុះអស់ ២៥% ។ វិស័យទេសចរណ៍ក៏រំពឹងថានឹងធ្លាក់ចុះដូចគ្នា ។ ការធ្លាក់ចុះរួមគ្នានៃវិស័យទាំងនេះ នឹងធ្វើឱ្យកំណើន ផសស ថយចុះ ដោយអ្នកវិភាគភាគច្រើនប៉ាន់ស្មានថា កំណើននឹងធ្លាក់ចុះមកត្រឹមពាក់កណ្តាលនៃកំណើនមធ្យមក្នុងទសវត្សរ៍កន្លងទៅនេះ ។នៅពេលវិបត្តិវិវត្តទៅមុខ ពួកអ្នកព្យាករណ៍ហាក់ដូចកាន់តែទុទិដ្ឋិនិយមឡើង ហើយការព្យាករណ៍ថ្មីៗបំផុត បានបង្ហាញថា ផសស របស់កម្ពុជានៅឆ្នាំនេះ នឹងមានកំណើនអវិជ្ជមាន ។

ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ វិស័យកសិកម្មមានកំណើន ៥% ក្នុងមួយឆ្នាំ ។ តួលេខនេះទំនងមិនផ្លាស់ប្តូរ ច្រើនទេ ដោយសារមិនសូវមានតម្រូវការពីក្រៅស្រុកលើផលិតផលកសិកម្ម ។ ប្រសិនបើមានការអនុម័ត គោលនយោបាយសមស្របសំរាប់គាំទ្រកសិកម្ម វិស័យនេះអាចជួយជំរុញកំណើន និងកាត់បន្ថយភាពក្រីក្រ ។

## ផលប៉ះពាល់លើភាពក្រីក្រ

កំណើនសេដ្ឋកិច្ចមានទំនាក់ទំនងផ្ទាល់ជាមួយការកាត់បន្ថយភាពក្រីក្រ ។ ផ្អែកលើកំណើនដ៏ខ្ពស់ នាពេលថ្មីៗ ការកាត់បន្ថយភាពក្រីក្រគួរតែខ្ពស់ខ្លាំងជាងកំរិត ១០% ដែលសំរេចបានក្នុងពេលកន្លងទៅ និងដែលកើតមានដូច្នេះឡើងដោយសារវិស័យមានកំណើនខ្ពស់ មានចំណងទាក់ទងតិចជាមួយវិស័យឯទៀតនៃសេដ្ឋកិច្ច ។ ការចូលរួមចំណែកសំខាន់បំផុតរបស់វិស័យមានកំណើនខ្ពស់ គឺការបង្កើតការងារ ហើយក្រៅពីនេះមិនសូវមានចំណងទាក់ទងអ្វីច្រើនជាមួយវិស័យឯទៀតទេ ប៉ុន្តែចំពោះទេសចរណ៍វាលក្ខណៈគ្រាន់បើជាងគេ ។

ដើម្បីអាចពិចារណាបានកាន់តែពេញលេញពី ផលប៉ះពាល់នៃការធ្លាក់ចុះកំណើនទៅលើភាពក្រីក្រ គេគួរធ្វើការបែងចែករវាងឥទ្ធិពលនៃកំណើនដែលផ្ទេរតាមរយៈទីផ្សារពលកម្ម និងផលប៉ះពាល់ទៅលើវិនិយោគ និងចំណាយប្រើប្រាស់ ។ ដោយសារមានចំណងទាក់ទងតិចរវាងវិស័យមាន

[1] បណ្ឌិត Hossein Jalilian ជាប្រធានផ្នែកស្រាវជ្រាវនៃ CDRI ។

ក្រាហ្វិក ២: ចំណែកតាមវិស័យ ក្នុងកំណើន ផសស នៅកម្ពុជា ១៩៩៤-២០០៧




*ប្រភព: វិទ្យាស្ថានជាតិស្ថិតិ*

កំណើនខ្ពស់ និងវិស័យឯទៀតនៃសេដ្ឋកិច្ច ឥទ្ធិពលដោយផ្ទាល់នៃការធ្លាក់ចុះកំណើនទៅលើភាពក្រីក្រ ដែលត្រូវបានផ្ទេរតាមរយៈទីផ្សារពលកម្ម ប្រហែលមិនសូវធ្ងន់ធ្ងរប៉ុន្មានទេ ។ ទោះយ៉ាងនេះក្តី ការបាត់បង់ការងារមិនមែនប៉ះពាល់តែលើសុខុមាលភាពរបស់ អ្នកគ្មានការងារធ្វើនោះទេ ប៉ុន្តែប៉ះពាល់ដល់ក្រុមគ្រួសារដែលបុគ្គលទាំងនោះផ្គត់ផ្គង់ផងដែរ ពីព្រោះជនចំណាកស្រុកពីតំបន់ជនបទទៅទីប្រជុំជនភាគច្រើន តែងផ្ញើប្រាក់ទៅភូមិកំណើតរបស់ខ្លួន ។

បន្ថែមលើចំណាកស្រុកពីជនបទទៅទីប្រជុំជន មានពលករកម្ពុជាប្រហែល ២៥.០០០នាក់ បានធ្វើចំណាកស្រុកទៅក្រៅប្រទេស ជាពិសេសទៅប្រទេសថៃ ។ ជនចំណាកស្រុកទាំងនេះមួយភាគធំ ទំនងត្រូវបាត់បង់ការងារ ដោយសារប្រទេសគោលដៅត្រូវវិបត្តិប៉ះពាល់ ក្នុងនេះអ្នកទៅប្រទេសថៃ ប្រហែលត្រូវជួបបញ្ហាធ្ងន់ធ្ងរជាង ។ លើសពី ៨០% នៃជនចំណាកស្រុកកម្ពុជាទៅថៃ ជាជនចំណាកស្រុកមិនស្របច្បាប់ ហើយអាជ្ញាធរថៃបានប្រកាសថា អ្នកទាំងនេះនឹងត្រូវបញ្ជូនត្រឡប់ទៅប្រទេសកំណើតវិញ ។ រឿងនេះ អាចប៉ះពាល់យ៉ាងខ្លាំងដល់ការប្រាក់ផ្ញើទៅផ្ទះ ហើយបន្ទាប់មកគឺសុខុមាលភាពរបស់ក្រុមគ្រួសារ ដែលបានប្រាក់ផ្ញើទាំងនេះជួយទ្រទ្រង់ ពីព្រោះពួកគេប្រើប្រាស់វាដើម្បីដោះស្រាយការចាយវាយផ្សេងៗ ក៏ដូចជាការចំណាយខាងធនធានមនុស្ស និងទ្រព្យរូបវន្ត ។

ការធ្លាក់ចុះកំណើន ជាពិសេសក្នុងកំរិតដែលបានព្យាករណ៍នាពេលថ្មីៗនេះ អាចប៉ះពាល់ខ្លាំងណាស់ទៅលើគ្រួសារនានា តាមការជះឥទ្ធិពលទៅលើចំណាយប្រើប្រាស់ និងវិនិយោគ ។ ប្រជាជនមួយភាគធំ មានកំរិតជីវភាពនៅកៀកនឹងបន្ទាត់ក្រីក្រ ដូច្នេះការធ្លាក់ចុះប្រាក់ចំណូលតែបន្តិច អាចរុញច្រានពួកគេ ឱ្យធ្លាក់ទៅក្រោមបន្ទាត់ក្រីក្រ ។ ការសិក្សាពីការចាកផុតពីភាពក្រីក្រដែល CDRI បានបោះពុម្ពផ្សាយកាលពីឆ្នាំមុន បានបង្ហាញច្បាស់ពីភាពងាយរងគ្រោះនេះ ។ ការសិក្សានៅភូមិមួយចំនួនបានបង្ហាញថា ការប្រែប្រួលប្រាក់ចំណូល ត្រឹមតែប៉ុន្មានរយរៀល ក៏អាចធ្វើឱ្យភាពក្រីក្រធ្ងន់ធ្ងរខ្លាំងឡើងដែរ ។ ការសិក្សានេះ ក៏បង្ហាញពីការផ្លាស់ប្តូរខ្លាំង គួរឱ្យកត់សំគាល់នៃអត្រា និងកំរិតធ្ងន់ធ្ងរនៃភាពក្រីក្រ រវាងរដូវវស្សា និងរដូវប្រាំង ផងដែរ ។ ដូច្នេះគេឃើញថា ប្រជាជនក្រីក្រមានមធ្យោបាយតិចតួចណាស់ សំរាប់ដោះស្រាយបញ្ហាប្រាក់ចំណូលប្រែប្រួលតាមរដូវកាល ។

ក្រៅពីឥទ្ធិពលអវិជ្ជមានទៅលើចំនួនការងារធ្វើ វិបត្តិក៏ប៉ះពាល់យ៉ាងខ្លាំងដល់ប្រជាជនក្រីក្រ និងក្រុមងាយរងគ្រោះផងដែរ ដោយសារការធ្លាក់ចុះសកម្មភាពសេដ្ឋកិច្ច ។ វាក៏ជះឥទ្ធិពលមិនល្អផងដែរទៅលើ អ្នកធូរធារគួរសម និងអ្នកមានៗ ។ អ្នកទាំងនេះប្រហែលធ្វើការកាត់បន្ថយចំណាយប្រើប្រាស់ និងជាពិសេស វិនិយោគ ។ ការធ្លាក់ចុះតំរូវការ និងចំណាយ នឹងជះឥទ្ធិពលដល់ប្រជាជនមួយភាគធំ ។ តាមធម្មតា ក្រុមដែលងាយបាត់បង់មធ្យោបាយទ្រទ្រង់ជីវភាពអស់មួយផ្នែក ឬទាំងមូល គឺ ក្រុមដែលគ្មាន ឬមិនសូវមានធនធានមនុស្ស និងមូលធនរូបវន្ត ហើយក្រុមទាំងនោះរួមមាន គ្រួសារក្រីក្រ និងក្រីក្រគួរសម ។

សរុបមក កម្ពុជាទំនងត្រូវប្រឈមមុខនឹងស្ថានភាពក្រីក្រកាន់តែធ្ងន់ធ្ងរ ប៉ុន្តែបញ្ហាធ្ងន់ធ្ងរដល់កំរិតណា ព្រមទាំងផលវិបាកផ្សេងៗទៀតនេះ វាជាប់ទាក់ទងនឹងដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជា ដូចជា សហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុប ជាដើម និងចំណុចថា តើប្រទេសទាំងនេះអាចទប់ទល់នឹងវិបត្តិបានល្អប៉ុណ្ណា ហើយជាពិសេស គឺ ប្រតិកម្មរបស់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ។

## ជម្រើសគោលនយោបាយ ដើម្បីទប់ទល់នឹងឥទ្ធិពលអវិជ្ជមាន

ការសិក្សាមួយដែល IMF ទើបបោះពុម្ពផ្សាយ បានចាត់ថ្នាក់កម្ពុជាចូលក្នុងចំណោម ប្រទេសមានប្រាក់ចំណូលទាបដែលងាយប៉ះពាល់ជាងគេ ។ ភាពងាយប៉ះពាល់នេះ គេវាស់វែងតាម កំណើនភាពងាយរងគ្រោះធ្លាក់ខ្លួនក្រីក្រ និងកំណើនជីវភាពលំបាករបស់គ្រួសារនានា ។ កត្តាសំខាន់ក្នុងនេះគឺត្រូវមានគោលនយោបាយ កាត់បន្ថយផលប៉ះពាល់នៃវិបត្តិទៅលើជនក្រីក្រភ្លាមៗ ឬក្នុងរយៈពេលខ្លី និងបំបាត់សំពាធដែលរារាំងកំណើន និងការកាត់បន្ថយភាពក្រីក្រ ក្នុងរយៈពេលមធ្យម និងវែង ។

ក្នុងពេលចំពោះមុខភ្លាមៗ និងក្នុងរយៈពេលខ្លី រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធ គួរដាក់អនុវត្តយន្តការនានា ដើម្បីជួយទ្រទ្រង់គ្រួសារក្រីក្រ និងក្រុមងាយរងគ្រោះ ។ យន្តការទាំងនេះអាចមានទម្រង់ជា ស្បៀងពលកម្ម ឧបត្ថម្ភធនលើស្បៀងអាហារនៅតាមសាលា និង ប័ណ្ណអាហារ ជាដើម ។ ពេលនេះក៏អាចជាឱកាសល្អ សំរាប់អនុវត្តកម្មវិធីសុវត្ថិភាពសង្គមប្រកបដោយប្រសិទ្ធភាពដែរ ដែលជួយយ៉ាងច្រើនដល់គ្រួសារក្រីក្រ និងមានផលល្អសំរាប់សេដ្ឋកិច្ច និងស្ថិរភាពនយោបាយ-សង្គមកិច្ច ទៀតផង ។

ទោះជាយ៉ាងនេះក្តី នៅមានឧបសគ្គមួយចំនួនដែលអាចរារាំងដល់ការងារខាងលើនេះ ។ ទោះបីជាមាន គោលនយោបាយល្អខាងហិរញ្ញវត្ថុ និងរូបិយវត្ថុក្តី ក៏រដ្ឋាភិបាលមិនទាន់មានសមត្ថភាពគ្រប់គ្រាន់លើផ្នែកហិរញ្ញវត្ថុ និងរូបិយវត្ថុទេ ដើម្បីអនុម័តប្រើគោលនយោបាយបង្កើនចំណាយថវិកាដ៏ចាំបាច់ទាំងនោះ ។ គោលនយោបាយខាងអត្រាប្តូរប្រាក់ បានកាត់បន្ថយជាខ្លាំងនូវតួនាទីនៃគោលនយោបាយខាងរូបិយវត្ថុ ហើយរដ្ឋាភិបាលមានជំរើសមិនច្រើនទេក្នុងការដាក់អនុវត្តគោលនយោបាយបង្កើនចំណាយថវិកា ព្រោះមានលទ្ធភាពតិចទាំងខាងថវិកា និងសមត្ថភាពដាក់អនុវត្តគោលនយោបាយទាំងនោះ ។ តួអង្គឯទៀតដូចជាដៃគូអភិវឌ្ឍន៍ជាដើម អាចដើរតួនាទីយ៉ាងសំខាន់ ប៉ុន្តែនៅក្នុងបរិយាកាសសេដ្ឋកិច្ចបច្ចុប្បន្ន លក្ខខណ្ឌនេះពុំកើតមានភ្លាមៗនោះទេ ទោះបីមានកិច្ចប្រឹងប្រែងក្នុងតំបន់ និងពិភពលោក ដើម្បីជួយទ្រទ្រង់ប្រទេសក្រីក្រក៏ដោយ ។

វិធានការរយៈពេលវែងគួរដាក់អនុវត្ត ដើម្បីកែលំអសន្តិសុខស្បៀង និងកាត់បន្ថយភាពងាយរងគ្រោះ ។ ការដាក់ចេញនូវគោលនយោបាយសមស្រប មានសារសំខាន់ណាស់ ដោយវាជួយជំរុញកំណើនមានលក្ខណៈរាប់បញ្ចូល ដែលក្នុងនោះប្រជាជនភាគច្រើនអាចទទួលបាននូវផ្លែផ្ការបស់វា ។ នៅដំណាក់កាលបច្ចុប្បន្ននៃការអភិវឌ្ឍ យុទ្ធសាស្ត្រប្រសើរបំផុតអាចជាការកាត់បន្ថយកត្តារារាំង និងសំពាធលើវិស័យកសិកម្ម ។ កត្តារារាំងមានជាច្រើន ហើយដោយសារកង្វះខាតធនធានមនុស្ស ហិរញ្ញវត្ថុ និងទ្រព្យរូបវន្ត សំរាប់ដោះស្រាយ ដូច្នេះគេត្រូវធ្វើការជ្រើសរើសដាក់អនុវត្តនូវ គោលនយោបាយទាំងឡាយណាដែលជួយកាត់បន្ថយ កត្តារាំងស្ទះខ្លាំងៗជាងគេ ។ កត្តារាំងស្ទះហាក់ដូចធ្ងន់ធ្ងរបំផុតលើផ្នែកហេដ្ឋារចនាសម្ព័ន្ធសង្គមនិងរូបវន្ត ។ កម្ពុជាស្ថិតក្នុងចំណោម ប្រទេសមានសមត្ថភាពប្រកួតប្រជែងតិចជាងគេនៅក្នុងតំបន់ ដែលបណ្តាលមួយចំណែកមកពី បន្ទុកចំណាយខ្ពស់ខាងពាណិជ្ជកម្ម និងផលិតកម្ម ។ ការដោះស្រាយឧបសគ្គខាងហេដ្ឋារចនាសម្ព័ន្ធ ទំនងជានឹងជួយកែលំអសមត្ថភាពប្រកួតប្រជែងនេះ ។

## សេចក្តីសន្និដ្ឋាន

ទោះបីវិបត្តិទំនងជះឥទ្ធិពលអវិជ្ជមានខ្លាំងមកលើកម្ពុជាក្តី ប៉ុន្តែវាបានផ្តល់ឱកាសឱ្យ រដ្ឋាភិបាលធ្វើការពិចារណាលើយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ខ្លួន ។ សមាសភាគសំខាន់បំផុត អាចជា ការអភិវឌ្ឍវិស័យកសិកម្មកាន់តែមានប្រសិទ្ធភាពខ្ពស់ និងស៊ីចង្វាក់គ្នា ដូចជា យុទ្ធសាស្ត្រសំរាប់ដោះស្រាយឧបសគ្គធំៗក្នុងវិស័យនេះ ជាដើម ។ ឧបសគ្គទាំងនេះ រួមមាន កង្វះវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសង្គម និងរូបវន្ត កង្វះខាតចំណេះទាក់ទងវារីវិស័យកសិកម្ម និងវិស័យឯទៀតក្នុងសេដ្ឋកិច្ច និង បញ្ហាខាងម៉ាឃីតធីងជាទូទៅ និងសំរាប់ផលិតផលកសិកម្មជាពិសេស ។

យុទ្ធសាស្ត្រទាំងឡាយខាងលើនេះ សុទ្ធតែពាក់ព័ន្ធគ្នាចុះឡើង ហើយវាមានផលប៉ះពាល់ច្រើនណាស់ទៅលើកំណើន និងភាពក្រីក្រ ។ ដោយឡែកគេគួរយកចិត្តទុកដាក់បន្ថែមលើ ការកាត់បន្ថយកត្តារាំងស្ទះដល់ផលិតកម្ម និងការលក់ស្រូវទាំងនៅក្នុង និងទៅក្រៅប្រទេស ។ អតិរេកស្រូវនៅកម្ពុជាមានលើសពី ២លានតោនក្នុងមួយឆ្នាំ ហើយការកែលំអប្រព័ន្ធធារាសាស្ត្រតែមួយមុខ ក៏អាចបង្កើនអតិរេកស្រូវទ្វេមួយជាពីរដែរ ។ ខុសពីផលិតផលកសិកម្មដទៃទៀត ថ្លៃស្រូវនៅទីផ្សារអន្តរជាតិបានកើនឡើងជាប់រហូតក្នុងទសវត្សរ៍នេះ ។ ទោះបីវាបានធ្លាក់ចុះខ្លះៗនៅពេលថ្មីៗក្តី ក៏ថ្លៃស្រូវនៅខ្ពស់ជាងកាលពីឆ្នាំមុននេះដែរ ហើយប្រាក់ចំណូលបានមកពីដំណាំស្រូវតែមួយមុខ ក៏អាចរួមចំណែកបានយ៉ាងច្រើនដល់សេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ៕